ទស្សនៈ អ្នកនិពន្ធ

វ៉ុល៤, លេខ៤, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២

# កំណែទម្រង់ ឬកំណែខ្លឹមសារ ក្នុងវិស័យអប់រំ?

បណ្ឌិត អ៊ុន លាង *

*នរណាដែលមិនប្រើវិធីដោះស្រាយថ្មី នឹងរង់ចាំសភាវៈអាក្រក់ថ្មីកើតឡើង ពីព្រោះពេលវេលា គឺជាអ្នកច្នៃប្រឌិតដ៏អស្ចារ្យ។ ហើយប្រសិនបើពេលវេលាបានផ្លាស់ប្តូរអ្វីៗឱ្យទៅជាអាក្រក់ជាងមុន ហើយប្រសិនបើគតិបណ្ឌិត និងការប្រឹក្សាយោបល់ មិនបានផ្លាស់ប្តូរអ្វីៗឱ្យប្រសើរជាងមុន តើអ្វីនឹងកើតមានឡើងនៅចុងក្រោយ? ~ Francis Bacon (1561–1626)*

ក្នុងឆ្នាំ២០២០ កម្ពុជាមានប្រជាជនសរុបចំនួន១៦,៧២លាននាក់ ក្នុងនោះប្រជាជនអាយុក្រោម៣៥ឆ្នាំ មានចំនួនច្រើនរហូតដល់ ៦៥,៦%។[1] ចំនួនប្រជាជនវ័យក្មេងនេះ នឹងដើរតួនាទីសំខាន់បំផុត សម្រាប់អនាគតកម្ពុជា ទាំងក្នុងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងនយោបាយផងដែរ។ ប៉ុន្តែសំណួរសួរថា តើពួកគេនឹងក្លាយជាភ្នាក់ងារជំរុញការអភិវឌ្ឍលើវិស័យទាំងនេះ ឬនឹងក្លាយជាបន្ទុកសង្គម?

ជាភ្នាក់ងារជំរុញការអភិវឌ្ឍលើវិស័យទាំងនេះ ឬជាបន្ទុកសង្គម គឺវាអាស្រ័យទាំងស្រុងទៅលើស្ថានភាពសុខភាពរាងកាយ និងកម្រិតបញ្ញាញាណរបស់ពួកគេ។ នៅទីនេះ យើងពិភាក្សាអំពីការអប់រំដែលតួនាទីរបស់វាក្នុងការបណ្តុះកម្រិតបញ្ញាញាណមនុស្ស គឺជាអ្វីដែលគេទទួលស្គាល់ជាសាកល។

ការអប់រំនៅកម្ពុជា ជាពិសេសការអប់រំតាមរយៈសាលារៀន និងសាកលវិទ្យាល័យ ដូចដែលយើងមានបទពិសោធន៍ក្នុងពេលនេះ បើធៀបជាមួយបណ្តាប្រទេសផ្សេងទៀត មិនមែនគ្រាន់តែយឺតជាងគេប៉ុណ្ណោះទេ តែថែមទាំងជួបភាពអាក់រអួល រងផលប៉ះពាល់ដោយសារសង្គ្រាមស៊ីវិលជាងពីរទសវត្សរ៍ និងជាពិសេសការលុបបំបាត់ការអប់រំ និងការកាប់សម្លាប់បញ្ញាជនក្នុងសម័យខ្មែរក្រហម។

ទើបតែឆ្នាំ១៩៩៣ មកទេ ពោលគឺក្រោយរដ្ឋាភិបាលថ្មីបានបង្កើតឡើងក្រោយការបោះឆ្នោត និងក្រោមជំនួយបរទេសជាបន្តបន្ទាប់ ដែលកំណែទម្រង់ និងកំណែខ្លឹមសារអប់រំទាំងស្រុងត្រូវបានធ្វើឡើង ដោយមិនគ្រាន់តែចាត់ទុកការអប់រំជាគន្លឹះនៃដំណើរការអភិវឌ្ឍន៍ប៉ុណ្ណោះទេ តែក៏ជាអ្វីដែលនាំកម្ពុជាចេញពីមនោគមន៍វិជ្ជាកុម្មុយនីស្ត និងសេដ្ឋកិច្ចផែនការទៅកាន់វិចារណកិច្ចអភិវឌ្ឍន៍ដ៏មានប្រជាប្រិយភាពនាពេលបច្ចុប្បន្ន ហៅថា ប្រជាធិបតេយ្យសេរី និងទីផ្សារសេរី។ នៅទីនេះ ខ្ញុំនឹងមិនពិភាក្សាថាតើវិចារណកិច្ចអភិវឌ្ឍន៍បែបនេះ គឺជាឧត្តមគតិសុក្រឹតដែលយើងត្រូវតែជឿជាក់នោះទេ ហើយក៏មិនវិភាគអំពីវិចារណកិច្ចនៃកំណែខ្លឹមសារអប់រំនាពេលកន្លងមកនោះដែរ ប៉ុន្តែគ្រាន់តែពិភាក្សាអំពីដំណើរការកំណែទម្រង់ និងជាពិសេសកំណែខ្លឹមសារអប់រំតែប៉ុណ្ណោះ។ ខ្ញុំជឿជាក់ថា ដំណើរការកំណែខ្លឹមសារ គឺជាដំណើរមិនឈប់ឈរ និងបើកចំហឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ដែលតម្រូវដាច់ខាតឱ្យត្រូវតែមានខ្លឹមសារបែបនេះ ឬបែបនោះ។

នៅចន្លោះឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ គេឃើញមានការស្រាវជ្រាវ និងសិក្ខាសាលាថ្នាក់ជាតិជាច្រើនត្រូវបានរៀបចំឡើង ដើម្បីស្វែងយល់អំពីស្ថានភាពអប់រំ និងស្វែងរកយុទ្ធសាស្ត្រកំណែទម្រង់អប់រំ

[1] ដកស្រង់ចេញពី https://data.worldbank.org/indicator/SP.POP.TOTL?locations=KH និងជំរឿនប្រជាជនឆ្នាំ២០១៩។

* **បណ្ឌិត អ៊ុន លាង** គឺជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ដោយបានបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលមានចំណងជើងថា *«កម្ពុជា៖ ការសិក្សាពីយុទ្ធសាស្ត្រវិស័យអប់រំ»* ដែលបានក្លាយជាប្រទីបសម្រាប់វិស័យអប់រំនៅកម្ពុជា។ ជាការពិត ការសម្រេចបានជោគជ័យនៅក្នុងវិស័យអប់រំ គឺផ្អែកលើកត្តាជាច្រើន ដូចជា ហិរញ្ញវត្ថុ អធិការកិច្ច គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំ/បណ្ដុះបណ្ដាល សាលារៀន គ្រូ ការចូលរួមរបស់អាណាព្យាបាល និងសហគមន៍ និងសិស្ស-និស្សិតខ្លួនឯងផ្ទាល់ ប៉ុន្តែស្នូលនៃការអប់រំដែលបណ្ដុះបញ្ញាញាណមនុស្ស គឺគោលនយោបាយកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។ ហើយនេះជាចំណុចស្នូលនៃប្រទីបសម្រាប់វិស័យអប់រំនៅពេលនោះផងដែរ។ វាពុំមានការសិក្សាលម្អិតទៅលើសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា និងគ្រប់កម្រិតនោះទេ ប៉ុន្តែនៅទីនេះ ដោយដកស្រង់ចេញពីមតិយោបល់របស់អ្នកពាក់ព័ន្ធ ការសិក្សាខ្លះៗ និងបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងវិស័យអប់រំ ខ្ញុំនឹងពិពណ៌នាគុណភាពនៃសៀវភៅសិក្សាគោលកន្លងមក ថាតើកម្រិតនៃការបណ្ដុះបញ្ញាញាណបានត្រឹមកម្រិតណា?

នៅក្នុងឆ្នាំ២០០២ លោក Jerry Walter បានកត់សម្គាល់ថា គោលដៅដែលចង់មានកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលក្នុងឆ្នាំ១៩៩៦ គឺបានសម្រេចដូចបំណង។ ប៉ុន្តែដោយផ្អែកតាមបទពិសោធន៍ក្នុងការអភិវឌ្ឍកម្មវិធីគណិតវិទ្យា និងរូបវិទ្យារបស់លោកផ្ទាល់ លោកបានអះអាងថា សៀវភៅសិក្សាគោលថ្មីមិនបានផលិតអ្វីថ្មីនោះទេ ប៉ុន្តែអ្វីដែលអាក្រក់បំផុតនោះ គឺវាផលិតសម្ភារឧបទេសបង្រៀន ដែលមានប្រយោជន៍តិចជាងសម្ភារឧបទេសចាស់ទៅទៀត។[2] ការសិក្សាពីគុណភាព និងភាពឆ្លើយតបនៃសិស្សដែលបញ្ចប់ការសិក្សាបានរកឃើញនូវចំណុចអវិជ្ជមានជាច្រើនក្នុងអំឡុងពេលនោះ។

ដោយមើលឃើញកង្វះខាតទាំងនេះ ក្នុងឆ្នាំ២០០៥ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញគោលនយោបាយកម្មវិធីសិក្សាថ្មី ហើយសៀវភៅសិក្សាគោលថ្មីត្រូវបានអភិវឌ្ឍឡើង។ ការសិក្សាលើមុខវិជ្ជាមួយចំនួន (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ដោយលោក ជេត ជាលី និងក្រុមស្រាវជ្រាវ ក្នុងឆ្នាំ២០១៤ បានរកឃើញថា ខ្លឹមសារមេរៀនមានលក្ខណៈស្មុគស្មាញ រប៉ាត់រប៉ាយ មិនមានការពន្យល់ឱ្យបានក្បោះក្បាយ និងមិនប្រកបដោយតក្កភាពនោះទេ។ បន្ថែមពីលើនេះ វាខ្វះសង្គតិភាពក្នុងកម្រិតនៃភាពស្មុគស្មាញ (ពីភាពសាមញ្ញទៅកាន់ភាពស្មុគស្មាញ ឬពីទាបទៅខ្ពស់) ហើយការសិក្សាពីបញ្ញត្តិមួយទៅកាន់បញ្ញត្តិមួយទៀត ក៏មិនមានលំដាប់លំដោយប្រកបដោយតក្កភាពនោះដែរ។ ឧទាហរណ៍ ខ្លឹមសារខ្លះនៅក្នុងមេរៀនថ្នាក់ទី៩ អាចចាត់ទុកថាគួរតែស្ថិតនៅក្នុងកម្រិតសាកលវិទ្យាល័យ។ ខ្លឹមសារមេរៀនជាសំខាន់ គឺផ្ដោតលើការចងចាំ ការយល់ និងការអនុវត្ត ហើយមានពេលខ្លះមិនត្រឹមត្រូវថែមទៀត។ សំណួរដូចជា «ដោយរបៀបណា?» និង «ហេតុអ្វី?» គឺមិនសូវមានទេ បើមានក៏នៅតែត្រូវចងចាំតាមចម្លើយដែលមាននៅក្នុងសៀវភៅគោល ហើយមិនមែនចេញពីការគិតរបស់សិស្សនោះទេ។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថា ខ្លឹមសារមិនមានការពាក់ព័ន្ធ ឬឆ្លើយតបទៅនឹងជីវភាពប្រចាំថ្ងៃ សង្គម និងបរិស្ថាននៅកម្ពុជា។ ចំណុចសំខាន់ដែលអវត្តមាន គឺជំនាញនៃការគិត ការសួរ ការកំណត់បញ្ហា ការរៀនសង្កេត ការប្រៀបធៀប ការចាត់ថ្នាក់ ការវិភាគ ការវាយតម្លៃ ការបញ្ជាក់ឡើងវិញ ក៏ដូចជាការបញ្ចេញគំនិតផ្ទាល់ខ្លួន។[3]

ការសិក្សាស្រដៀងគ្នានេះ ប៉ុន្តែផ្ដោតលើគ្រប់មុខវិជ្ជាពីថ្នាក់ទី១០ ដល់ទី១២ និងមុខវិជ្ជាបង្រៀននៅថ្នាក់ឆ្នាំមូលដ្ឋាននៅកម្រិតឧត្តមសិក្សា ដោយខ្ញុំផ្ទាល់ (អ៊ុន លាង) និងក្រុមស្រាវជ្រាវនៅក្នុងឆ្នាំ២០១៤ ក៏បានរកឃើញដូចគ្នាទៅនឹងការរកឃើញខាងលើដែរ។ វាមានការយកចិត្តទុកដាក់ខ្លាំងទៅលើការរម្លឹក និងការចងចាំជាជាងការអភិវឌ្ឍការយល់ដឹងកម្រិតខ្ពស់តាមរយៈការរៀន និងការអនុវត្តវិធីសាស្ត្រផ្សេងៗ ដែលជាប់ទាក់ទងនឹងការវិភាគឱ្យបានស៊ីជម្រៅ ការសំយោគគំនិត និងការបង្កើតគំនិតថ្មី។ ដូចគ្នានឹងការ

[2] សូមមើល Walter, J. (2002). $500,000 a year. The Phnom Penh Post, 18 January 2002។

[3] សូមមើល Chet, C., Ngin, C., Chhinh, S., Dy, S. & Ford, D. (2014). Reviews of Educational Contents, Pedagogies and Connectivity of Curriculum and its Relevance to Economic Development in Cambodia. Phnom Penh: Royal University of Phnom Penh and Capacity Development Partnership Fund។

សិក្សាខាងលើដែរ ចំណេះដឹងនៅក្នុងសៀវភៅសិក្សាគោលទាំងអស់ ស្ទើរតែមិនមានការនិយាយពាក់ព័ន្ធនឹងសង្គមកម្ពុជា លើកលែងតែមុខវិជ្ជាភាសា ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ និងវប្បធម៌ខ្មែរ។ តាមរយៈសៀវភៅសិក្សាដែលពួកគេរៀននៅឆ្នាំចុងក្រោយនៃថ្នាក់វិទ្យាល័យ សិស្សពុំត្រូវបានរៀបចំឱ្យមានការច្នៃប្រឌិត ការគិតពិចារណាឱ្យបានស៊ីជម្រៅ ការប្រើប្រាស់កុំព្យូទ័រ ជំនាញធ្វើបទបង្ហាញ ជំនាញស្រាវជ្រាវ ជំនាញក្នុងការរៀននៅមន្ទីរពិសោធន៍ និងជំនាញអក្ខរកម្មព័ត៌មានសម្រាប់ការអប់រំនៅសាកលវិទ្យាល័យឡើយ។

សំណួរអំពីប្រព័ន្ធនៃការប្រឡងក៏ត្រូវបានលើកឡើងដែរ នៅក្នុងការសិក្សានេះ។ តើអ្វីដែលបានលើកយកមកប្រឡងនៅពេលប្រឡងថ្នាក់ទី១២ គឺជាការឆ្លុះបញ្ចាំងពីការចងចាំដ៏ល្អ ឬការយល់ដឹងស៊ីជម្រៅ? តើអ្វីទៅដែលត្រូវបានឱ្យតម្លៃដោយប្រព័ន្ធអប់រំនាពេលបច្ចុប្បន្ន? តើវាជាការរម្លឹកឡើងវិញ និងការចងចាំ ឬជាការសិក្សាសម្រាប់ការយល់ដឹង និងការរៀនអំពីរបៀបនៃការរៀនសូត្រ?

នៅក្នុងកម្រិតឧត្តមសិក្សា ពុំទាន់មានការសិក្សាឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយទេ តែការសិក្សាលើមុខវិជ្ជាថ្នាក់ឆ្នាំមូលដ្ឋាន បានរកឃើញពីភាពច្រំដែលនៃមេរៀនកម្រិតឧត្តមសិក្សា និងថ្នាក់វិទ្យាល័យ។[4] សម្រាប់មុខវិជ្ជាជំនាញនៅឆ្នាំបន្តបន្ទាប់ វាស្ទើរតែគ្មានសៀវភៅសិក្សាគោល ដែលពិភាក្សាអំពីសង្គមកម្ពុជា ពីព្រោះសៀវភៅទាំងនោះភាគច្រើននាំចូល ឬថតចម្លងពីបរទេស សរសេរជាភាសាបរទេស (អង់គ្លេស) លើកលែងមុខវិជ្ជាភាសា ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ និងវប្បធម៌ខ្មែរ។

ក្នុងឆ្នាំ២០១៦ ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសត្រូវបានដាក់ចេញម្តងទៀតដោយក្រសួងអប់រំ យុវជន និងកីឡា ប៉ុន្តែរហូតមកទល់ពេលនេះ គេពុំទាន់ឃើញមានការអភិវឌ្ឍសៀវភៅសិក្សាគោលថ្មីនៅឡើយទេ លើកលែងតែការកែសម្រួល និងកែលម្អបន្តិចបន្តួចទៅលើសៀវភៅសិក្សាគោលចាស់ដែលអភិវឌ្ឍក្រោមការចង្អុលទិសពីគោលនយោបាយកម្មវិធីសិក្សាឆ្នាំ២០០៥ តែប៉ុណ្ណោះ។

រហូតមកទល់ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឯកសារណែនាំការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សា៖ មុខវិជ្ជាសង្គម ក្រោមការជួយជ្រោមជ្រែងពីសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា ប្រទេសជប៉ុន នៅតែចាត់ទុកថា កម្មវិធីសិក្សា និងសៀវភៅសិក្សាគោលជាធនធានអប់រំដ៏សំខាន់បំផុតក្នុងការបង្រៀន និងរៀន ហើយទទួលស្គាល់ថាការអភិវឌ្ឍឯកសារទាំងនេះ អាចមានលក្ខណៈខុសគ្នាទៅតាមបរិបទ សម័យកាល និងស្ថានភាពសង្គម តែឯកសារទាំងនោះមិនត្រូវបានចងក្រងទុកជាក្បួនខ្នាត ឬសេចក្តីណែនាំសម្រាប់អ្នកជំនាន់ក្រោយនោះទេ។[5] ខ្ញុំឯកភាពជាមួយមតិដែលថា សៀវភៅសិក្សាគោលជាធនធានអប់រំដ៏សំខាន់បំផុតក្នុងការបង្រៀន និងរៀន។ ជាការពិត សៀវភៅសិក្សាគោល គឺជាគម្ពីរចំណេះដឹងតែមួយគត់សម្រាប់សិស្សកម្ពុជា ជាពិសេសអ្នកដែលនៅជនបទ។

ហេតុនេះ តើអ្វីដែលជំនាន់នេះត្រូវធ្វើ? ២៩ឆ្នាំបានកន្លងផុតទៅបន្ទាប់ពីឆ្នាំ១៩៩៣មក កម្ពុជានៅពុំទាន់មានកម្មវិធីសិក្សា និងជាពិសេសសៀវភៅសិក្សាគោលសម្រាប់បណ្តុះបណ្តាញញាណប្រជាជនរបស់ខ្លួន ឱ្យបានសមស្របនៅឡើយ។ តាមពិត វដ្តនៃការអប់រំដោយមិនគិតពីថ្នាក់ក្រោយបរិញ្ញាបត្រ មានថេរវេលា១៦ឆ្នាំ។ ហេតុនេះ ប្រសិនបើនៅមុនឆ្នាំ២០២៩ កម្ពុជាមិនអាចមានកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលដែលល្អសមស្រប សម្រាប់បណ្តុះបណ្តាញញាណប្រជាជនរបស់ខ្លួនទេ កម្ពុជានឹងបាត់បង់ឱកាសក្នុងការចាប់យកយុគមាសដែលទទួលផលប្រយោជន៍ពីចំនួនប្រជាជនដ៏ច្រើនលើសលុបដែលមានវ័យក្រោម៣៥ឆ្នាំ ពីព្រោះចាប់ពីក្រោយឆ្នាំ២០៤៥ទៅ កម្ពុជានឹងជួបប្រទះនូវកង្វះកម្លាំងពលកម្ម ដូចដែលប្រទេសមួយចំនួននៅក្នុងតំបន់កំពុងជួបប្រទះ រួមមានទាំងសិង្ហបុរី ម៉ាឡេស៊ី និងថៃជាដើម នេះបើតាមការវិភាគពីវឌ្ឍនភាព

[4] សូមមើល Un, Leang, et al. 2014. "Senior Secondary School Curriculum Reform in Cambodia: Relevance for employment and tertiary education", Manuscript, Education Master Program, Royal University of Phnom Penh។

[5] ក្រសួងអប់រំ យុវជន និងកីឡា (២០២០). ឯកសារណែនាំការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សា៖ មុខវិជ្ជាសង្គម។

ប្រជាសាស្ត្រ។[6] ក្នុងន័យនេះ កម្ពុជានៅសល់តែ៧ឆ្នាំតែប៉ុណ្ណោះសម្រាប់ធ្វើកិច្ចការមួយនេះ។

សម្រាប់ខ្ញុំ អ្វីដែលកើតមាននៅក្នុងវិស័យអប់រំនាពេលបច្ចុប្បន្ននេះ គឺការសង្កត់ធ្ងន់លើប្រសិទ្ធភាព និងប្រសិទ្ធផល ដែលចេញពីកំណែទម្រង់អភិបាលកិច្ច និងគណនេយ្យភាព។ អ្វីដែលត្រូវបានមើលរំលង ឬបំភ្លេចចោល គឺខ្លឹមសារដែលត្រូវតែមានក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ដែលយើងត្រៀមដើម្បីបណ្ដុះបញ្ញាញាណរបស់ប្រជាជនខ្មែរ សម្រាប់នាំមកនូវវឌ្ឍនភាពដល់សង្គមកម្ពុជា។ ក្នុងន័យនេះ កំណែទម្រង់ត្រូវតែយល់ក្នុងផ្លូវខ្លឹមសារ ដែលជាជាង *កែទម្រង់* យើងត្រូវ *កែខ្លឹមសារ*។ ចេញពីការកែខ្លឹមសារកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលដ៏ត្រឹមត្រូវ ដែលជាដំណើរការ *កំណែខ្លឹមសារ* វានឹងត្រួសត្រាយផ្លូវសម្រាប់ណែនាំ*កំណែទម្រង់*ផ្នែកហិរញ្ញវត្ថុ អធិការកិច្ច គណៈគ្រប់គ្រងគ្រឹះស្ថានអប់រំ/បណ្ដុះបណ្ដាល សាលារៀន គ្រូ ការចូលរួមរបស់អាណាព្យាបាល និងសហគមន៍ និងសិស្ស-និស្សិតខ្លួនឯង ដើម្បីឈានទៅសម្រេចបានការបណ្ដុះបញ្ញាញាណតាមកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។ កំណែទម្រង់ដោយមិនកែកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលឱ្យបានត្រឹមត្រូវ គឺជាកំណែទម្រង់ដែលឥតខ្លឹមសារ។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
The Kampus Building, Unit 1D, Street 93, Sangkat Tonle Bassac, Khan Chamkarmon
info@cd-center.org | (+855) 10 950 456 www.cd-center.org

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[6] សូមមើល National Employment Agency. 2018. Skill shortages and skill gaps in Cambodian labour market: Evidence from Employer Survey 2017. Phnom Penh: National Employment Agency។